County of Los Angeles
dpss DEPARTMENT OF PUBLIC SOCIAL SERVICES

CalFresh FOOD

# ការទទួលបានប្រយោជន៍ជំនួយ CalFresh (ES) កម្មវិធីម្ហូបអាហារ យ៉ាងឆាប់រហ័សបាន

## អ្នកអាចមានលក្ខណសម្បត្តិទទួលបានអត្ថប្រយោជន៍ CalFresh (ES) យ៉ាងឆាប់រហ័សក្នុងរយៈពេល 3 ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំរបស់អ្នកត្រូវបានទទួល ។

## អ្នកត្រូវតែបំពេញតាមតម្រូវការមួយខាងក្រោម ៖

1. ប្រាក់ចំណូល និងធនធានងាយបង្វិលជាសាច់ប្រាក់រួមបញ្ចូលគ្នារបស់អ្នកគឺតិចជាងថ្លៃឈ្នួលផ្ទះ ឬប្រាក់បង់រំលស់ថ្លៃផ្ទះ (ប្រាក់កម្ចីពីធនាគារ) និងថ្លៃ ទឹក ភ្លើង ហ្គាសប្រចាំខែរបស់អ្នក ។
2. ក្រុមគ្រួសាររបស់អ្នកមានប្រាក់ចំណូលសរុបប្រចាំខែ $150 ឬតិចជាងនេះ និង ធនធានងាយបង្វិលជាសាច់ប្រាក់របស់អ្នកមានចំនួន $100 ឬតិចជាងនេះ
3. នរណាម្នាក់នៅក្នុងក្រុមគ្រួសាររបស់អ្នកគឺជាអ្នកធ្វើការងារ (កម្មករ) ដែលផ្លាស់ពីកន្លែងមួយទៅកន្លែងមួយទៀត ឬជាកសិករតាមរដូវកាលដែលក្រខ្សត់ និងមានធនធានងាយបង្វិលជាសាច់ប្រាក់ចំនួន $100 ឬតិចជាងនេះ ។

អ្នក**នឹងត្រូវ**បានធ្វើការបទសម្ភាសន៍ ហើយអត្តសញ្ញាណរបស់អ្នក ត្រូវតែបានបញ្ជាក់ថាត្រឹមត្រូវ (ប័ណ្ណសំគាល់ខ្លួនដែលមានរូបភាពមិនត្រូវបានតម្រូវទេ) ។ យើងអាចជួយអ្នកក្នុងការបញ្ជាក់អត្តសញ្ញាណរបស់អ្នក ដែលសមហេតុផលទាំងអស់ តាមរយៈការហៅទូរស័ព្ទទៅភាគីទីបី (នរណាម្នាក់ដែលអ្នកស្គាល់) ឬឯកសារ ឬព័ត៌មានអេឡិចត្រូនិកដែលអាចរកបាន ។

អ្នកអាចនឹងត្រូវបានធ្វើការបទសម្ភាសន៍ **នៅថ្ងៃតែមួយដែលអ្នកបានដាក់ពាក្យស្នើសុំ** ឬក៏ការណាត់ជួបបទសម្ភាសន៍តាមទូរស័ព្ទ នឹងត្រូវបានកំណត់ក្នុងរយៈពេលបីថ្ងៃ ។ ទោះយ៉ាងណាក៏ដោយ អ្នកអាចទូរស័ព្ទមកយើងគ្រប់ពេល មុនពេលការណាត់ជួបដែលបានកំណត់ពេលរបស់អ្នក ។

ប្រសិនបើអ្នកមានលក្ខណសម្បត្តិទទួលបាន CalFresh (ES) យ៉ាងឆាប់រហ័ស ហើយ អ្នកមិនបានទទួលបានអត្ថប្រយោជន៍របស់អ្នកក្នុងរយៈពេល 3 ថ្ងៃ ។ ប័ណ្ណផ្ទេរអត្ថប្រយោជន៍អេឡិចត្រូនិក (EBT) និងលេខកូដសម្ងាត់ (PIN) សុវត្ថិភាពនឹងត្រូវបានផ្ញើមកឱ្យអ្នកតាមប្រៃសណីយ៍ ឬដោយទៅយកវាពីការិយាល័យខណ្ឌ ។

**ទូរស័ព្ទតាមលេខ (866) 613-3777 (ឥតគិតថ្លៃ) | (626) 569-1399 | (310) 258-7400 | (818) 701-8200**

ជាដំបូងចុចជម្រើស #2 **"Apply for Benefits,"**

ហើយចុចជម្រើស #2 **"CalFresh Apply,"**ម្តងទៀតដើម្បីភ្ជាប់ទៅអ្នកកាន់សំណុំរឿងនៅពេលដែលអ្នកទូរស័ព្ទហៅ។

**ម៉ោងបើកធ្វើការនៅមជ្ឈមណ្ឌលសេវាអតិថិជន ៖**
ពីថ្ងៃច័ន្ទ ដល់ ថ្ងៃសុក្រ ចាប់ពីម៉ោង 7:30 am ដល់ម៉ោង 7:30 pm
និង ថ្ងៃសៅរ៍ ចាប់ពីម៉ោង 8:00 am ដល់ម៉ោង 4:30 pm ។



Cambodian